NSW GOVERNMENT | Education

ការប្រឆាំងនឹងការសម្លុតធ្វើបាប

# គន្លឹះសម្រាប់មាតាបិតា និងអ្នកថែទាំ

ព្រឹត្តិបត្រព័ត៌មាន

## តើការសម្លុតធ្វើបាបជាអ្វី ?

### ការសម្លុតធ្វើបាបមានលក្ខណៈពិសេសសំខាន់បី។ វា៖

- ពាក់ព័ន្ធនឹងការប្រើប្រាស់អំណាចខុសក្នុងទំនាក់ទំនង
- កំពុងបន្តម្តងហើយម្តងទៀត ហើយ
- ពាក់ព័ន្ធនឹងឥរិយាបថដែលអាចបណ្តាលឱ្យមានគ្រោះថ្នាក់។

**ការសម្លុតធ្វើបាប**ក៏អាចកើតមានតាមអនឡាញដែរ។ ការនេះគេស្គាល់ថា ការគំរាមកំហែងតាមអ៊ីនធើរណិត (cyberbullying) ដែលប្រើប្រាស់បច្ចេកវិទ្យាដូចជាអ៊ីនធើរណិត ឬឧបករណ៍ចល័ត ដើម្បីសម្លុតធ្វើបាបនរណាម្នាក់។ វាអាចរួមបញ្ចូលទាំងការផ្ញើសារ និងអ៊ីម៉េលដែលប្រមាថ ការបង្ហោះសារដែលធ្វើឱ្យឈឺចាប់ និងការសរសេរមតិយោបល់មិនសមរម្យ នៅលើរូបភាពរបស់អ្នកដទៃ។

**ការសម្លុតធ្វើបាប**ប្រភេទណាមួយ គឺមិនអាចទទួលយកបានឡើយ នៅសាលារៀនរដ្ឋ NSW ទោះជាមានហេតុផលអ្វីក៏ដោយ។ សាលារៀនបានប្តេជ្ញាចិត្តធ្វើការជាមួយមាតាបិតា សិស្ស បុគ្គលិក និងសិស្សដើម្បីទប់ស្កាត់ការសម្លុតធ្វើបាប ហើយឆ្លើយតបយ៉ាងរហ័ស និងមានប្រសិទ្ធភាព ប្រសិនបើវាកើតមានឡើង។

## តើលោកអ្នកអាចធ្វើអ្វីខ្លះ ប្រសិនបើកូនរបស់លោកអ្នកត្រូវបានគេសម្លុតធ្វើបាប ?

### សូមស្តាប់ដោយស្ងៀមស្ងាត់ ហើយយល់ដឹងពីសាច់រឿងឱ្យបានពេញលេញ

កូនរបស់លោកអ្នកត្រូវការដឹងថា មានគេកំពុងស្តាប់ពួកគេ។ អារម្មណ៍របស់ពួកគេមានសារសំខាន់ណាស់ ហើយក្តីបារម្ភរបស់ពួកគេ គួរតែបានយកចិត្តទុកដាក់យ៉ាងខ្លាំង។ លើកទឹកចិត្តឱ្យកូនរបស់លោកអ្នកនិយាយពីអ្វីដែលបានកើតឡើង។ ពន្យល់ប្រាប់កូនរបស់លោកអ្នកថា មិនអីទេដែលរាយការណ៍ពីករណីសម្លុតធ្វើបាប។

បន្ទាប់ពីបានស្តាប់ក្តីបារម្ភរបស់ពួកគេហើយ សួរសំណួរដើម្បីទទួលបានព័ត៌មានលម្អិតបន្ថែម បើចាំបាច់៖ តើនរណា អ្វីទៅ នៅកន្លែងណា នៅពេលណា។

### ពង្រឹងទំនុកចិត្តកូនរបស់លោកអ្នកថា ពួកគេមិនត្រូវរងការស្តីបន្ទោសឡើយ

កុមារអាចបន្ទោសខ្លួនឯង ហើយការនេះអាចធ្វើឱ្យពួកគេមានអារម្មណ៍រឹតកាន់តែអាក្រក់។ សូមនិយាយពីអ្វីដែលផ្តល់ការគាំទ្រដូចជា ‘ស្តាប់ទៅពិតជាពិបាកក្នុងការដោះស្រាយ’ ឬ ‘ប៉ាម៉ាក់ពិតជារីករាយណាស់ដែលកូនបានប្រាប់ពួកយើង។ កូនគួរតែមានអារម្មណ៍សុវត្ថិភាពនៅសាលារៀន’។

### សួរកូនរបស់លោកអ្នកពីអ្វីដែលពួកគេចង់ធ្វើ - និងអ្វីដែលពួកគេចង់ឱ្យលោកអ្នកធ្វើ

វាសំខាន់ត្រូវជួយកូនរបស់លោកអ្នក ស្វែងរកដំណោះស្រាយផ្ទាល់របស់ខ្លួន ពីព្រោះការនេះនឹងជួយឱ្យពួកគេមានអារម្មណ៍ថា ពួកគេមានការគ្រប់គ្រងខ្លះទៅលើស្ថានភាព។

ប្រសិនបើកូនរបស់លោកអ្នក មិនស្ថិតនៅក្នុងគ្រោះថ្នាក់ណាមួយភ្លាមនោះទេ ហើយពួកគេមានអារម្មណ៍ជឿជាក់ ពួកគេអាចសាកល្បងយុទ្ធសាស្ត្រទាំងនេះ៖

- មិនអើពើចំពោះការសម្លុតធ្វើបាប។
- បែរខ្នងដាក់ រួចដើរចេញ។
- ធ្វើដូចជាមិនចាប់អារម្មណ៍ ឬធ្វើពុតថាពួកគេមិនខ្វល់។
- និយាយថា «ទេ» ឬ «ឈប់ធ្វើ!» យ៉ាងម៉ឺតម៉ាត់។

ប្រសិនបើមានករណីសម្លុតធ្វើបាបបានកើតឡើងនៅសាលារៀន ត្រូវគាំទ្រដល់កូនរបស់លោកអ្នកឱ្យប្រាប់គ្រូបង្រៀន។ ប្រសិនបើកូនរបស់លោកអ្នកចង់និយាយទៅកាន់នរណាម្នាក់ ក្រៅពីសាលារៀន ឬលោកអ្នកគិតថា ការគាំទ្របន្ថែមនឹងអាចជួយបាន លោកអ្នកអាចប្រាប់ពួកគេឱ្យបើកចូលវិបសាយខ្សែទូរស័ព្ទជំនួយសម្រាប់កុមារ (Kids Helpline)។ ពួកគេក៏អាចហៅ ទូរស័ព្ទដោយឥតគិតថ្លៃដែរ លេខ 1800 55 1800។

### តើខ្ញុំត្រូវទាក់ទងសាលារៀននៅពេលណា ?

កូនរបស់លោកអ្នក អាចនឹងមានការស្ទាក់ស្ទើរដើម្បីឱ្យលោកអ្នកនិយាយទៅកាន់បុគ្គលិកសាលា។ សូមពិភាក្សាអំពីគំនិត ហើយធានាដល់ពួកគេថាសាលារៀនមុខជាចង់ដឹង ហើយអាចជួយបាន។

ក្នុងករណីចាំបាច់ សូមធ្វើការណាត់ជួបជាមួយគ្រូបង្រៀនរបស់កូនលោកអ្នក។ លោកអ្នកក៏អាចនិយាយជាមួយនាយកសាលាបានដែរ។

សូមទាក់ទងមកសាលារៀនភ្លាមៗ ប្រសិនបើលោកអ្នកមានក្តីបារម្ភ អំពីសុវត្ថិភាពរបស់កូនលោកអ្នក

### ការគាំទ្រសម្រាប់មាតាបិតា និងអ្នកថែទាំ

ខ្សែទូរស័ព្ទជំនួយសម្រាប់កុមារ (Kids Helpline) ក៏មានខ្សែទូរស័ព្ទសម្រាប់មាតាបិតាដែរ ជាមួយនឹងក្រុមដែលបានទទួលការបណ្តុះបណ្តាល ដែលផ្តល់ការគាំទ្រ ព័ត៌មាន និងការផ្តល់ប្រឹក្សាសម្រាប់មាតាបិតាកុមារអាយុ០-១៨ឆ្នាំ លោកអ្នកអាចទូរស័ព្ទទៅកាន់គេដោយបង់ថ្លៃទូរស័ព្ទដូចក្នុងតំបន់ ចាប់ពីម៉ោង៩ព្រឹក ទៅម៉ោង៩យប់ ពីថ្ងៃច័ន្ទ ទៅថ្ងៃសុក្រ និងម៉ោង៤រសៀល ទៅម៉ោង៩យប់ នៅថ្ងៃចុងសប្តាហ៍ លេខ 1300 1300 52។

### សេវាអ្នកបកប្រែភាសាតាមទូរស័ព្ទ

ប្រសិនបើលោកអ្នកមានបំណងចង់ទាក់ទងមកសាលារៀន ឬខ្សែទូរស័ព្ទសម្រាប់មាតាបិតា NSW (Parent Line NSW) ហើយត្រូវការជំនួយជាមួយភាសាអង់គ្លេស សូមទូរស័ព្ទសេវាអ្នកបកប្រែភាសាតាមទូរស័ព្ទលេខ 131 450 និយាយប្រាប់គេនូវភាសាដែលលោកអ្នកត្រូវការ ហើយស្នើសុំប្រតិបត្តិករឱ្យទូរស័ព្ទជូនលោកអ្នក។ ប្រតិបត្តិករនឹងរៀបចំអ្នកបកប្រែភាសាជូនលោកអ្នកតាមទូរស័ព្ទ ដើម្បីជួយលោកអ្នកធ្វើការសន្ទនា។ សេវានេះនឹងពុំគិតថ្លៃពីលោកអ្នកឡើយ។